## ២-សេចក្តីសំរេច

រាជធានីភ្នំពេញ,ថ្ងៃទី០៤ ខែ កញ្ញា ឆ្នាំ ២០០០

### សេចក្តីសំរេច លេខ ៥៨ សសរ

### ស្តីពី

### ការផ្ទេរសិទ្ធិ នៃរាជរដ្ឋាភិបាល

* * *

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

### សំរេច

ប្រការ ១ : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្តេចនាយករដ្ឋមន្ត្រី ដែលត្រូវអញ្ជើញទៅចូលរួមជំនួបកំពូលសហស្សវត្សរ៍ នៃអង្គការសហប្រជាជាតិ ចាប់ពីថ្ងៃទី០៤ ខែ កញ្ញា ឆ្នាំ ២០០០ រហូតដល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា អញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

ប្រការ ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នប្រតិភូរាជរដ្ឋាភិបាល អភិបាលគ្រប់ខេត្ត ក្រុង និងឯកឧត្តម ស ខេង ត្រូវអនុវត្តសេចក្តី សំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

រាជធានីភ្នំពេញ,ថ្ងៃទី០៨ ខែ កញ្ញា ឆ្នាំ ២០០០

### សេចក្តីសំរេច លេខ ៥៩ សសរ

### ស្តីពី ការបង្កើតគណៈកម្មការដើម្បីទប់ស្កាត់ទឹកជំនន់

* * *

### រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមការចាំបាច់ របស់រាជរដ្ឋាភិបាល

**សំរេច**

**ប្រការ ១ :** បង្កើតគណៈកម្មការមួយដើម្បីទប់ស្កាត់ទឹកជំនន់ជុំវិញរាជធានីភ្នំពេញ ដែលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១-ឯកឧត្តម លឹម គានហោ | រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម | ប្រធាន |
| ២-ឯកឧត្តម ស៊ុំ ម៉ានិត | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៣-ឯកឧត្តម អ៊ុក រ៉ាប៊ុន | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤-ឯកឧត្តម ច័ន្ទ សុខអ៊ីវ | រដ្ឋលេខាធិការក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៥-ឯកឧត្តម ចាយ សាំងយុន | រដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| ៦-ឯកឧត្តម ត្រាំ អ៊ីវតឹក | រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ៧-ឯកឧត្តម ម៉ម ប៊ុនហេង | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ៨-ឯកឧត្តម ម៉ាន់ សារិន | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអភិបាលរងរាជធានីភ្នំពេញ | សមាជិក |
| ៩-ឯកឧត្តម ឧ.សេនីយ៍ឯក ស៊ូ ផន | អគ្គនាយករងទី១នគរបាលជាតិ | សមាជិក |
| ១០-ឯកឧត្តម ពៅ សាមី | អគ្គលេខាធិការនៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | លេខាធិការ |

**ប្រការ ២ :** គណៈកម្មការនេះមានភារកិច្ច ៖

-លើកផែនការ និងរៀបចំកំលាំងប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញ និងមន្ត្រីរាជការតាមក្រសួងស្ថាប័ន ដើម្បីលើកទំនប់ទប់ស្កាត់ទឹកជំនន់ ដែលកំពុងគំរាមកំហែងមកលើរាជធានីភ្នំពេញ

-ត្រៀមជួយជំលៀសប្រជាពលរដ្ឋចេញពីកន្លែងដែលទឹកជន់លិច

-ត្រៀមស្បៀង ថ្នាំពេទ្យ និងសំភារៈចាំបាច់នានា សំរាប់ឧបត្ថម្ភជនរងគ្រោះ ។

ប្រធានគណៈកម្មការត្រូវអញ្ជើញសមាជិកប្រជុំ និងចាត់ចែងការងារជាបន្ទាន់ ដើម្បីត្រៀមដោះស្រាយអោយទាន់សភាពការណ៍ ។

ប្រការ ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអភិបាលរាជធានីភ្នំពេញ និងសមាសភាពគណៈកម្មការ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេច ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី ស្តីទី

ហត្ថលេខានិងត្រា

ស ខេង

***

## ៣- សារាចរ

រាជធានីភ្នំពេញ,ថ្ងៃទី០៥ ខែ កញ្ញា ឆ្នាំ ២០០០

### សារាចរ លេខ ០២ សរ

### ស្តីពី

### ការចាត់តាំងរៀបចំពិធីបុណ្យចំរើនព្រះជន្ម ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងគម្រប់ព្រះជន្ម ៧៨ យាងចូល ៧៩ ព្រះវស្សា បុណ្យខួបអនុស្សាវរីយ៍លើកទី ៤៧ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា និងបុណ្យ អុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក

* * *

• ពិធីបុណ្យចំរើនព្រះជន្ម ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទិពោរពសក្ការៈ ក្នុងគម្រប់ព្រះជន្ម ៧៨ យាងចូល ៧៩ ព្រះវស្សា នឹងត្រូវប្រព្រឹត្តទៅចំនួន ៣ថ្ងៃ ចាប់ពីថ្ងៃទី៣០-៣១ តុលា ដល់ថ្ងៃ ០១ វិច្ឆិកា ២០០០ ខាងមុខនេះ ដើម្បីសំដែងកតញ្ញូតាធម៌ចំពោះព្រះមហាករុណាធិគុណ ថ្វាយព្រះពរសព្ទសាធុការ និងថ្វាយមហាកុសលចំពោះ ព្រះករុណាជាម្ចាស់ជីវិតលើត្បូង ទ្រង់មានព្រះជន្មាយុយឺនយូរ ព្រះសុខមាលភាពល្អបរិបូណ៌ ព្រះកាយពលរឹងមាំ និងព្រះបញ្ញាញាណភ្លឺថ្លា ដើម្បីបានគង់ប្រថាប់នៅជាម្លប់ដ៏ត្រជាក់របស់ ប្រជារាស្ត្រខ្មែរយូរអង្វែងតរៀងទៅ ។

• ពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី ៤៧ នៃទិវាបុណ្យឯករាជ្យជាតិ នឹងត្រូវប្រព្រឹត្តទៅ នៅថ្ងៃទី០៩ ខែ វិច្ឆិកា ឆ្នាំ ២០០០ ដើម្បីសំដែងមនោសញ្ចេតនាអបអរសាទរ រំលឹកទិវាជាប្រវត្តិសាស្ត្រ ដែលកំលាំងមហាសាមគ្គីជាតិទាំងមូលផ្តើមបានទាំងស្រុងមកវិញពីអាណានិគមនិយមបារាំង នាឆ្នាំ ១៩៥៣ នូវឯករាជ្យជាតិដ៏ពិតប្រាកដ ក្រោមព្រះរាជបូជនីយកិច្ចដ៏ថ្លៃថ្លា នៃ ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ។

• ពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក នឹងត្រូវប្រព្រឹត្តទៅចំនួន ៣ថ្ងៃ គឺថ្ងៃ ១៤-១៥កើត និងថ្ងៃ ១រោច ខែកត្តិក ត្រូវនឹងថ្ងៃទី ១០-១១-១២ ខែ វិច្ឆិកា ឆ្នាំ ២០០០ ដើម្បីបើកឱកាសជូន